JobAccess

Driving disability employment

# បណ្ណព័ត៌មាន

# មជ្ឈមណ្ឌលផ្តល់ព័ត៌មានស្តីពីការងារ (JOBACCESS)

JobAccess ជាមជ្ឈមណ្ឌលថ្នាក់ជាតិសំរាប់ផ្តល់ពត័មានទាក់ទងនឹងកន្លែងធ្វើការ និងការងារ
សំរាប់បណ្តាជនមានពិការភាព និយោជក និងអ្នកផ្តល់សេវានានា ។

JobAccess ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលអូស្ត្រាលីដើម្បីប្រមូលផ្តុំពត័មាន និងធនធានទាំងឡាយ ដែលអាច
‘ជំរុញឲ្យមានការងារសំរាប់ជនពិការ’ ។

JobAccess អាចជួយបណ្តាជនដែលមានពិការភាពស្វែងរកនិងរក្សាការងារ
ទទួលការតំលើងតំណែងទៅធ្វើការងារដែលកាន់តែប្រសើរ ទទួលបានការឧបត្ថម្ភហិរញ្ញវត្ថុ
និងការគាំទ្រផ្សេងដទៃទៀត បង្កើនជំនាញការងារ និងអ្វីៗច្រើនទៀត ។

JobAccess អាចជួយឲ្យនិយោជកពេញចិត្តនឹងភាពសំបូរបែបនៅទីកន្លែងធ្វើការ
យល់ពីផលប្រយោជន៍នៃការទទួលយកជនពិការមកធ្វើការ បង្កើតការងារសំរាប់ជនពិការ
ជ្រើសរើសនិងរក្សាមនុស្សដែលត្រូវនឹង ការងារ ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការគាំទ្រដ៏ទៃទៀត បង្កើតយុទ្ធសាស្រ្ត
និងផែនការការងារសម្រាប់ជនពិការ និងអ្វីៗច្រើនទៀត ។

JobAccess អាចជួយឲ្យអ្នកផ្តល់សេវាការងារយល់ពីតួនាទីរបស់ខ្លួន
និងបង្កើតសេវានានាដើម្បីឆ្លើយតបយ៉ាងល្អបំផុតទៅនឹងតម្រូវការរបស់ជនពិការ និងអ្វីៗច្រើនទៀត ។

គេហទំព័ររបស់ JobAccess មានពត័មានជាច្រើនដូចជា ៖ ការជួយគាំទ្រខាងហិរញ្ញវត្ថុសំរាប់ការកែ កន្លែងការងារ
និងការជួយឧបត្ថមប្រាក់បៀវត្ស  យោបល់ក្នុងការរើសបុគ្គលិកពេលដាក់ពាក្យសុំការងារ
និងជ្រើសរើសយកបុគ្គលិកដែលមានពិការភាព  ភ្ជាប់ទៅនឹងកម្មវិធីអប់រំនិងបណ្តុះបណ្តាល
ការលាតត្រដាងព័ត៌មានអំពីពិការភាព  សិទ្ធិនិងការទទួលខុសត្រូវនានារបស់ទាំងអ្នកដែលមានពិការភាព ទាំងនិយោជក
ឧបករណ៍និងធនធាននានាសំរាប់និយោជក និងវិធីធ្វើយ៉ាងណាដើម្បីបង្កើតបរិយាកាសការងារដែលងាយបត់បែនមួយ
ហើយនិងខ្សែទំនាក់ទំនងជាមួយកម្មវិធីជំនួយនិងផ្សេងៗរបស់រដ្ឋាភិបាល ។

សំរាប់ពត័មានបន្ថែមសូមមើលគេហទំព័រ JobAccess នៅ www.jobaccess.gov.au
ឬក៏ទាក់ទងមកអ្នកផ្តល់យោបល់របស់ JobAccess តាមរយៈលេខ 1800 464 800
- ការទាក់ទងតាមទូរសព្ទ័ដៃត្រូវគេគិតថ្លៃ។

Australian Government

JobAccess is the national hub for workplace and employment information for people with disability, employers and service providers.

**1800 464 800** **www.jobaccess.gov.au**